**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ២០០៥ សហវ.វិស

រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែមករា ឆ្នាំ ២០១១

**គោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម**

**កម្មវត្ថុ:** សំណើសុំគោលការណ៍ចំណាយថវិកាជំពូក២១ « គម្រោងវិនិយោគផ្ទាល់» ចំនួន ២ ១៥៧ ៧៧៦ ៤៩៨រៀល ជូននាយកដ្ឋានវិស្វកម្មនៃក្រសួងធនធានទឹកនិងឧតុនិយម សម្រាប់ជួសជុលទំនប់អាងទឹកអូរយ៉េះ ស្ថិតនៅឃុំស្រែសង្គម ស្រុកកោះញែក ខេត្តមណ្ឌលគីរី ។

**យោង:**
- ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១១ លើលិខិតលេខ ៧៩១២ សហវ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លិខិតលេខ ០៤៤ ធទឧ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១១ របស់ក្រសួងធនធានទឹកនិងឧតុនិយម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ សូមជម្រាបឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមផ្តល់ជានាចំណាយជូនចំនួន ២ ០៨១ ០០០ ០០០ រៀល (ពីរពាន់ប៉ែតសិបមួយលានរៀលគត់) ដោយប្រើប្រាស់ឥណទានថវិកាជំពូក ២១ « គម្រោងវិនិយោគផ្ទាល់» សម្រាប់ឲ្យនាយកដ្ឋានវិស្វកម្មនៃក្រសួងធនធានទឹកនិងឧតុនិយម អនុវត្តការងារជួសជុលទំនប់អាងទឹកអូរយ៉េះ ស្ថិតនៅឃុំស្រែសង្គម ស្រុកកោះញែក ខេត្តមណ្ឌលគីរី រួមមាន ៖

- ជួសជុលទំនប់អាងទឹកអូរយ៉េះ ប្រវែង ៤.៤៥០ម
- សាងសង់សំណង់ទ្វារទឹក ទ្វារ១ លើទំនប់អូរយ៉េះ ចំនួន ០៤កន្លែង

សេចក្តីដូចបានជម្រាបខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ ។

សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន**
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សាលាខេត្តមណ្ឌលគីរី
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តមណ្ឌលគីរី
- នាយកដ្ឋានវិស្វកម្មក្រសួងធនធានទឹកនិងឧតុនិយម «ដើម្បីមុខការ »
- ឯកសារ-កាលប្បវត្តិ